# ការធ្វើតេស្តរកមើលជំងឺ COVID-19

វាមានសារៈសំខាន់ណាស់ក្នុងការធ្វើតេស្ត ប្រសិនបើអ្នកមានរោគសញ្ញា ឬ ប្រសិនបើអ្នកប៉ះពាល់ផ្ទាល់ជាមួយនរណាម្នាក់ដែលបានធ្វើតេស្តវិជ្ជមានរកឃើញជំងឺ COVID-19។

## កន្លែងដែលអ្នកអាចទទួលការធ្វើតេស្ត

អ្នកផ្តល់សេវាថែទាំសុខភាពរបស់អ្នក ឬអ្នកផ្តល់សេវាដែលទទួលយកការធានារ៉ាប់រងរបស់អ្នក។

កន្លែងធ្វើតេស្តដែលអាចបើកបរ ឬដើរចូលបាន។

គ្លីនិករបស់សហគមន៍ មណ្ឌលសុខភាព ឬឱសថស្ថាន។

## ថ្លៃចំណាយ

ប្រសិនបើអ្នកមានរោគសញ្ញា ឬមានប៉ះពាល់ផ្ទាល់ជាមួយនរណាម្នាក់ដែលធ្វើតេស្តវិជ្ជមានរកឃើញជំងឺ **COVID-19** ការធ្វើតេស្តរបស់អ្នក គួរតែឥតគិតថ្លៃ។

- ប្រសិនបើអ្នកទទួលបានការធានារ៉ាប់រង ក្រុមហ៊ុនធានារ៉ាប់រងរបស់អ្នក ត្រូវតម្រូវឲ្យរ៉ាប់រងលើថ្លៃចំណាយនៃការធ្វើតេស្ត។ ទូរសព្ទទៅសាកសួរជាមុនថាតើវាអាចមានការគិតថ្លៃសេវាផ្សេងៗដែរឬទេ។
- ប្រសិនបើអ្នកមិនទទួលបានការធានារ៉ាប់រងទេ កន្លែងដែលអាចបើកបរចូលបាន គ្លីនិករបស់សហគមន៍ និងមណ្ឌលសុខភាពជាច្រើន ផ្តល់ការធ្វើតេស្តដោយឥតគិតថ្លៃ ទោះគ្មានការធានារ៉ាប់រងក៏ដោយ។ អ្នកផ្តល់សេវាដទៃទៀត អាចធ្វើការជាមួយអ្នក ដើម្បីឲ្យការធ្វើតេស្តរបស់អ្នកត្រូវបានធានារ៉ាប់រង។

## របៀបក្នុងការធ្វើតេស្ត

ទូរសព្ទទៅអ្នកផ្តល់សេវារបស់អ្នក ឬទូរសព្ទទៅលេខដែលនៅខាងក្រោយប័ណ្ណធានារ៉ាប់រងរបស់អ្នក។

- ទូរសព្ទទៅលេខ 2-1-1។
- សូមចូលទៅកាន់Washington State Department of Health (ក្រសួងសុខាភិបាលរដ្ឋវ៉ាស៊ីនតោន)គេហទំព័រនៃទីតាំងធ្វើតេស្ត៖ doh.wa.gov/TestingLocations.

សូមចូលទៅកាន់ **DOH.WA.GOV/Coronavirus** សម្រាប់ព័ត៌មានបន្ថែម។

ដើម្បីស្នើសុំឯកសារនេះជាទម្រង់ផ្សេងទៀត សូមទូរសព្ទទៅលេខ 1-800-525-0127។ អតិថិជនគថ្លង់ ឬពិបាកក្នុងការស្តាប់ សូមទូរសព្ទទៅលេខ 711 (Washington Relay) ឬអ៊ីម៉ែល civil.rights@doh.wa.gov

DOH 820-100 September 2020 – Khmer

Washington State Department of Health

# ការធ្វើតេស្តរកមើលជំងឺ COVID-19



## ការណាត់ជួបធ្វើតេស្តរបស់អ្នក

### 1 ចុះឈ្មោះសម្រាប់ការណាត់ជួបរបស់អ្នក។




កន្លែងដែលអាចបើកបរចូលបាន និងគ្លីនិករបស់សហគមន៍ នឹងសាកសួរអ្នកអំពី៖

- ព័ត៌មានទូទៅ ដូចជាឈ្មោះ និងព័ត៌មានទំនាក់ទំនងរបស់អ្នក ដើម្បីឲ្យពួកគេអាចទាក់ទងទៅផ្តល់លទ្ធផលទៅអ្នក។
- អត្តសញ្ញាណប័ណ្ណ និងប័ណ្ណធានារ៉ាប់រងរបស់អ្នក។ អ្នកមិនត្រូវបានតម្រូវឲ្យបង្ហាញពួកវាទេ ប៉ុន្តែពួកគេនឹងសួររកវា។

ពួកគេនឹងមិនសួរអំពីស្ថានភាពអន្តោប្រវេសន៍របស់អ្នកទេ។ ព័ត៌មានរបស់អ្នក នឹងត្រូវបានចែករំលែកតែជាមួយនឹង Department of Health (ក្រសួងសុខាភិបាល) ឬផ្នែកសុខាភិបាលតាមមូលដ្ឋានរបស់អ្នកតែប៉ុណ្ណោះ។

### 2 ការធ្វើតេស្ត។



អ្នកផ្តល់សេវានឹងប្រមូលគំរូសំណាកពីអ្នក។ ជាធម្មតា ពួកគេនឹងជូតផ្នែកខាងក្នុងច្រមុះរបស់អ្នក ឬឲ្យអ្នកជូតច្រមុះរបស់អ្នកដោយខ្លួនឯងផ្ទាល់។



បន្ទាប់មក គំរូសំណាករបស់អ្នកត្រូវបញ្ជូនទៅក្នុងបន្ទប់ពិសោធន៍សម្រាប់ការធ្វើតេស្ត។

### 3 នៅផ្ទះ។



ត្រូវប្រាកដថាអ្នកស្ថិតនៅក្នុងផ្ទះ និងនៅឆ្ងាយពីអ្នកដទៃ រហូតទាល់តែអ្នកដឹងលទ្ធផលនៃការធ្វើតេស្តរបស់អ្នក។

សម្រាប់ព័ត៌មានបន្ថែមស្តីពីការធ្វើតេស្តជំងឺ COVID-19 សូមចូលទៅកាន់៖ **doh.wa.gov/Testing**